**AUSTRALIAN EMBASSY**
**PHNOM PENH**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០

**អូស្ត្រាលីសន្យាផ្តល់ថវិកាចំនួន១៦លានដុល្លាអាមេរិច ដើម្បីការល្អប្រសើរឡើងវិញក្រោយពីជំងឺកូវីដ-១៩ ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-អូស្ត្រាលី**

អូស្ត្រាលីឃើញអាស៊ានជាស្នូលនៃតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក។ ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-អូស្ត្រាលីម្សិលមិញ រដ្ឋមន្ត្រីការបរទេស សមាជិកព្រឹទ្ធសភាអូស្ត្រាលី លោកជំទាវ Marise Payne ពង្រឹងការតាំងចិត្តរួមរបស់អូស្ត្រាលី ក្នុងការរក្សាតំបន់អោយនៅជាតំបន់បើកចំហរ សន្តិភាព ស្ថេរភាព និងអនុវត្តតាមច្បាប់ គោលការណ៍ទស្សនវិស័យរបស់អាស៊ានពីឥណ្ឌូ-ប៉ាស៊ីហ្វិក និងការប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិតក្នុងតំបន់។

សុខភាព និងសេដ្ឋកិច្ចរបស់អូស្ត្រាលី ចងភ្ជាប់ជិតស្និទ្ធជាមួយដៃគូអាស៊ីអាគ្នេយ៍របស់យើង ហើយអាស៊ាននៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតបនឹងជំងឺកូវីដ-១៩។

ក្នុងកិច្ចប្រជុំម្សិលមិញ សមាជិកព្រឹទ្ធសភា Payne ដាក់ចេញផែនការពីវិធីដែលអូស្ត្រាលីអាចបង្កើនកិច្ចសហប្រតិបត្តិការជាមួយអាស៊ីអាគ្នេយ៍ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងជួយធ្វើផែនការស្តារសេដ្ឋកិច្ចជារួម។

សមាជិកព្រឹទ្ធសភា Payne បានប្រកាសពីកញ្ចប់ថវិកាថ្មីចំនួន១៦លានដុល្លាអាមេរិច ដើម្បីជួយទ្រទ្រង់ដល់ការស្តារឡើងវិញនូវ សន្តិសុខសុខាភិបាល ស្ថេរភាព និងសេដ្ឋកិច្ច របស់ប្រទេសជាសមាជិកអាស៊ាន។

កញ្ចប់ថវិកានេះរួមមានៈ

- ផ្នែក **សុខភាពសុខាភិបាល** គំនិតផ្តួចផ្តើមថ្មីនេះ ផ្តោតលើការកាត់បន្ថយហានិភ័យនៃជំងឺរាតត្បាត តាមរយៈ ការបង្កើនទំនាក់ទំនងនិងសហការរវាងស្ថាប័ន កែលំអរទម្លាប់អនាម័យនៅតាមផ្សារសត្វរស់ និងបន្ថែមអាហារូបករណ៍និងកម្មវិធីសិក្សានៅអូស្ត្រាលី។

- ផ្នែក **ស្ថេរភាព** ភាពជាដៃគូនយោបាយ-សន្តិសុខ អាស៊ាន-អូស្ត្រាលីថ្មី នឹងពង្រឹងការឆ្លើយតបទៅនឹងបញ្ហារួម ដូចជា សន្តិសុខតាមសមុទ្រ សន្តិសុខតាមអ៊ីនធឺណែត ឧក្រិដ្ឋកម្មឆ្លងដែន ព្រមទាំងសន្តិសុខ និងសន្តិភាពរបស់ស្ត្រី បន្ថែមលើ ការគាំទ្របន្ថែមដើម្បីជួយសហគមន៍កម្មករចំណាកស្រុកដែលងាយរងគ្រោះ មានលទ្ធភាពទទួលបានការធ្វើចំណាកស្រុកដោយមានសុវត្ថិភាព។

- ផ្នែក **ស្តារសេដ្ឋកិច្ច** ជាការបន្តគំនិតផ្តួចផ្តើមស្តង់ដារពាណិជ្ជកម្មតាមអ៊ីនធឺណែត អាស៊ាន-អូស្រ្តាលីដែលទទួលបានជោគជ័យ ដើម្បីធានាថាពាណិជ្ជកម្មតាមអ៊ីនធឺណែត ជួយជំរុញការស្តារសេដ្ឋកិច្ចរបស់តំបន់ ដល់ឆ្នាំ២០២២ ព្រមទាំងគាំទ្រដល់ផែនការស្តារឡើងវិញបន្ទាប់ពីជំងឺរាតត្បាត របស់អាស៊ាន ដែលផ្តោតសំខាន់លើវិធីសាស្រ្តរួមក្នុងតំបន់ទាំងមូល។

កញ្ចប់ថវិកានេះបន្ថែមលើដៃគូយុទ្ធសាស្រ្តធំទូលាយរបស់អូស្រ្តាលី ជាមួយអាស៊ាន ព្រមទាំងការងារទ្វេភាគីសំខាន់ៗ ដែលកំពុងធ្វើនៅទូទាំងតំបន់ រួមមានតាមរយៈ ដៃគូអភិវឌ្ឍទ្វេភាគីរបស់អូស្រ្តាលី និងកម្ពុជា។

ឯកឧត្តម Pablo Kang ឯកអគ្គរាជទូតអូស្រ្តាលីប្រចាំនៅកម្ពុជា បានមានប្រសាសន៍ថា៖ “យើងទាំងអស់គ្នាមានចំណែកលើសន្តិសុខក្នុងតំបន់របស់យើង ហើយកិច្ចសហប្រតិបត្តិការមានសារសំខាន់ប្រសិនបើយើងចង់ជៀសវាងមិនអោយមានវិបត្តិសុខភាព និងសេដ្ឋកិច្ចយូរអង្វែង។”

“កម្ពុជានឹងអាចទទួលបានកញ្ចប់ថវិការបស់គំនិតផ្តួចផ្តើមតំបន់សម្រាប់អាស៊ាននេះ ដែលនឹងបន្ថែមលើការងារដែលយើងកំពុងតែធ្វើ តាមរយៈ ដៃគូអភិវឌ្ឍទ្វេភាគីរបស់យើង ដើម្បីជួយដល់ការឆ្លើយតបរបស់កម្ពុជាទៅនឹងជំងឺកូវីដ-១៩។”

“ដើម្បីអូស្រ្តាលីនិងកម្ពុជា និងដើម្បីតំបន់រួមយើងទាំងមូល ដោះស្រាយបញ្ហាដែលមិនធ្លាប់មាននេះ ទាមទារកិច្ចសហប្រតិបត្តិការអន្តរជាតិកម្រិតដែលមិនធ្លាប់មានផងដែរ។”

“ជំនួសការបែរខ្នងចេញ យើងនឹងឈរជាមួយគ្នាក្នុងពេលមានការរាតត្បាតនេះ ដូចដែលយើងធ្លាប់ពេលមានវិបត្តិកន្លងមក ក្នុងនាមជាដៃគូពិភាក្សាយូរអង្វែងរបស់អាស៊ាន។”

**ទំនាក់ទំនងព័ត៌មានបន្ថែម**
ស្ថានទូតអូស្រ្តាលី Australian.Embassy.Cambodia@dfat.gov.au



រដ្ឋមន្ត្រីការបរទេស សមាជិកព្រឹទ្ធសភាអូស្ត្រាលី  លោកជំទាវ Marise Payne  ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-អូស្ត្រាលី
**រូបថត៖** Facebook ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា